# របៀបមើលលក្ខណៈបុរស

## ១-រាងទាបតឿ

បុរសដែលមានរូបរាងមិនដល់ ១ម៥០ គេចាប់ទុកជាមនុស្សទាបតឿ មនុស្សបែបនេះមាន ទោសៈមោហៈក្នុងខ្លួនច្រើនណាស់ ហើយជាមនុស្សដែលសំបូរទៅដោយល្បិចកិច្ចកលជាច្រើន មនុស្សជំពូកនេះពុំសូវមានរោមច្រើនទេ ។

## ២-រាងមធ្យម

មនុស្សដែលមានកំពស់ពី ១ម៦០ទៅដល់១ម៧០ គេចាត់ទុកជាជំពូកមនុស្សដែលមានរាង មធ្យម ឬហៅថាកំពស់ពេញខ្នាត មនុស្សបែបនេះច្រើនមានចរិយាល្អ គួរសេពគប់រាប់អានគ្នា ។

## ៣-រាងដូចស្រី

បុរសដែលមានរាងដូចស្រី ចូលចិត្តតែដូរ្យតន្ត្រី មានចិត្តស្ម័គ្រស្មាគមន៍ជាមួយនឹងនារី ឬបុរសដែលមានរូបរាងដូចខ្លួន ។

## ៤-រាងខ្ពស់

បុរសដែលមានកំពស់ចាបពី ១ម៧០ឡើងទៅ គេចាត់ទុកជាជំពូកមនុស្សមានរាងខ្ពស់ ។ មនុស្សបែបនេះប្រសិនបើមានរូបរាងអវៈយវៈសមនឹងកំពស់ នោះមានចរិយាល្អប្រសើរណាស់ ផ្ទុយទៅវិញ បើដៃជើង និងមាឌមិនសមគ្នាទេ គឺជាមនុស្សដែលមានចរិយាមិនល្អ ។

## លក្ខណៈបបូរមាត់

១-បបូរមាត់ស្តើង

បុរសណាដែលមានបបូរមាត់ស្តើង ជាមនុស្សដែលមានចរិយាល្អ ស្រឡាញ់ជីវភាព តែចូលចិត្ត រអ៊ូរទាំ និងនិយាយស្តីច្រើន ។

## ២-បបូរមាត់ក្រាស់

បុរសណាដែលមានបបូរមាត់ក្រាស់ ហើយក្រហម ជាមនុស្សដែលចូលចិត្តតាមតណ្ហា និងល្មោភ ស៊ី ជាមនុស្សមានចិត្តស្ពឹកទំរន់ក្នុងការងារ ។